ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ថ្ងៃទី 14 ខែ 07 ឆ្នាំ 10
ម៉ោង 9H60'

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ: ០៤៩/១០ កប/ការងារ

# សេចក្តីជូនដំណឹង

គោរពតាមអនុសាសន៍ជាគោលការណ៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងចំពោះអង្គការសហជីពគ្រប់ថ្នាក់ សមាគមនិយោជក កម្មករនិយោជិត និងនិយោជកនៃរោងចក្រ សហគ្រាស គ្រឹះស្ថានផ្នែកវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើងទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា នៅថ្ងៃទី០៨ ខែ កក្កដា ឆ្នាំ២០១០ គណៈកម្មការប្រឹក្សាការងារ ដែលមានតំណាងមកពីរដ្ឋាភិបាល តំណាងមកពីខាងអង្គការសហជីព និងតំណាងមកពីសមាគមនិយោជក បានធ្វើការប្រជុំពិភាក្សាគ្នា អំពីប្រាក់ឈ្នួលអប្បបរមារបស់កម្មករនិយោជិត ផ្នែកវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើង ។

អង្គប្រជុំបានសម្រេចលទ្ធផល ដូចខាងក្រោមនេះ :-

១-ប្រាក់ឧបត្ថម្ភជីវភាពចំនួន **៦** (ប្រាំមួយ)ដុល្លារ អាមេរិក ដែលបានសម្រេចកាលពីឆ្នាំ២០០៨ ត្រូវបញ្ចូលទៅក្នុងប្រាក់ឈ្នួលគោលរបស់កម្មករនិយោជិតផ្នែកវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើងគ្រប់ៗគ្នា ។

២-កំណត់ប្រាក់ឈ្នួលអប្បបរមារបស់កម្មករនិយោជិត ផ្នែកវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើង ចំនួន **៥៦** (ហាសិបប្រាំមួយ) ដុល្លារអាមេរិកក្នុងមួយខែ សម្រាប់កម្មករនិយោជិតសាកល្បងពី **១**ខែ ទៅ **៣**ខែ (គឺប្រាក់ឈ្នួលអប្បបរមាបច្ចុប្បន្ន **៤៥** ដុល្លារ បូកប្រាក់តម្លើង **៥** ដុល្លារ បូកប្រាក់ឧបត្ថម្ភជីវភាព **៦** ដុល្លារ ស្មើ **៥៦** ដុល្លារ) ។ ចប់រយៈពេលសាកល្បងកម្មករនិយោជិតពេញសិទ្ធិ ត្រូវទទួលប្រាក់ឈ្នួលអប្បបរមាចំនួន **៦១**(ហុកសិបមួយ) ដុល្លារ អាមេរិកក្នុងមួយខែ (គឺប្រាក់ឈ្នួល អប្បបរមាបច្ចុប្បន្ន **៥០** ដុល្លារ បូកប្រាក់តម្លើង **៥** ដុល្លារ បូកប្រាក់ឧបត្ថម្ភជីវភាព **៦** ដុល្លារ ស្មើ **៦១** ដុល្លារ) ។

៣-ចំពោះកម្មករនិយោជិត ដែលទទួលប្រាក់ឈ្នួលគិតតាមបរិមាណផលិតផល (ដេរស៊ីបុង) ត្រូវបានប្រាក់ឈ្នួលតាមទិន្នផលជាក់ស្តែងដែលធ្វើបាន ។ បើទិន្នផលការងារទទួលបាននោះលើសពីចំនួនប្រាក់ឈ្នួល



អាសយដ្ឋានអគារលេខ ៣ មហាវិថីសហព័ន្ធរុស្ស៊ី. សង្កាត់ទឹកល្អក់១. ខណ្ឌទួលគោក. ភ្នំពេញ ប្រអប់សំបុត្រ P.O Box 1506 ទូរស័ព្ទ: (៨៥៥-២៣) ៨៨៤-៣៧៥. Fax: ៨៨២-៧៦៥

ដែលមានចែងក្នុងចំណុចទី២ ខាងលើត្រូវទទួលបានតាមការលើសនោះ ។ ប្រសិនបើទាបជាង និយោជកត្រូវបន្ថែមឱ្យគ្រប់ចំនួន **៥៦** ដុល្លារ អាមេរិកក្នុងមួយខែ សម្រាប់កម្មករនិយោជិតធ្វើការសាកល្បង និងចំនួន **៦១** ដុល្លារ អាមេរិកក្នុងមួយខែ សម្រាប់កម្មករនិយោជិតពេញសិទ្ធិ ។

៤-អត្ថប្រយោជន៍ផ្សេងទៀត ដែលកម្មករនិយោជិតធ្លាប់បានទទួលតាមសេចក្តីជូនដំណឹងលេខ **០១៧** សកបយ. ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០០០ ត្រង់ចំណុចទី៣,ទី៤,ទី៥ និងទី៦ ត្រូវរក្សាទុក និងមានសុពលភាពអនុវត្តដដែល ។

ចំណុចទី១, ទី២ និងទី៣ នៃសេចក្តីជូនដំណឹងនេះត្រូវអនុវត្តចាប់ពីថ្ងៃទី០១ ខែ តុលា ឆ្នាំ២០១០ រហូតដល់ឆ្នាំ២០១៤ ។ នៅឆ្នាំ២០១៤ គណៈកម្មការប្រឹក្សាការងារនឹងធ្វើការពិនិត្យពិភាក្សាឡើងវិញ អំពីបញ្ហាប្រាក់ឈ្នួលអប្បរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើង ។

សេចក្តីជូនដំណឹងរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លេខ **៧៤៥** ក.ក.ប.វ. ចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ២០០៦ និងសេចក្តីជូនដំណឹងលេខ **០៣២/០៨** កប/សជណ. ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ២០០៨ ត្រូវទុកជានិរាករណ៍ ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា កម្មករនិយោជិត អង្គការសហជីព សមាគមនិយោជក និងនិយោជក នៃរោងចក្រ សហគ្រាស គ្រឹះស្ថាន ផ្នែកវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើងទាំងអស់នឹងអនុវត្តតាមសេចក្តីជូនដំណឹងនេះបានល្អប្រសើរ និងធានាបាននូវប្រសិទ្ធភាពខ្ពស់ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ២០១០

**រដ្ឋមន្ត្រី**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**វង្ស សុត**

**ចម្លងជូនៈ**

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យលោកជំទាវ ឧបនាយករដ្ឋមន្ត្រី ប្រចាំការ
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួង ស្ថាប័ន ពាក់ព័ន្ធ

"**ដើម្បីជូនជ្រាប**"

- អគ្គនាយកដ្ឋានការងារ
-គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី-ខេត្ត
-គ្រប់សមាគមនិយោជក
-គ្រប់សហព័ន្ធសហជីព

"**ដើម្បីផ្សព្វផ្សាយ និងអនុវត្ត**"

-រាជកិច្ច
-កាលប្បវត្តិ-ឯកសារ